ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សាលាព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខ: ១០៨១
ចុះថ្ងៃទី ១៦-១១-២០១២
សាលដីកា
លេខ ៖ ០២ "ក្រ.III.ស"
ចុះថ្ងៃទី ២៤-០១-២០១៣

# ក្នុងនាមប្រជារាស្ត្រខ្មែរ
# សាលាឧទ្ធរណ៍ភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី ១៤ ខែមករា ឆ្នាំ២០១៣ ដោយមានសមាសភាព ដូចខាងក្រោម:

## ក្រុមប្រឹក្សាជំនុំជម្រះ

- លោក [redacted] ជាប្រធានក្រុមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា
- លោកស្រី [redacted] ជាចៅក្រមប្រឹក្សា

## តំណាងមហាអយ្យការ

លោក [redacted]

## ក្រឡាបញ្ជី

កញ្ញា [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ ១០៨១ ចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ២០១២ ដែលមាន:

- ជនជាប់ចោទឈ្មោះ [redacted] បុត្រទី ភេទប្រុស អាយុ ២៥ឆ្នាំ ជាតិខ្មែរ មុខរបរមិនពិតប្រាកដ កើត និងរស់នៅភូមិប៉ែអឹម [redacted] ខេត្តប៉ៃលិន ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) នៅលីវ ទោសគ្មានពីមុន។ មានលោក [redacted] ទ្រី និងលោក [redacted] ឆាយ ជាមេធាវីការពារ។

ជាប់ចោទពីបទ: លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចផ្ទះហ្គេមម្លូកហាត់សាច់ដុំ ផ្លូវលេខ ៦៣ កែងផ្លូវលេខ ១៨០ សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី ១១ ខែមីនា ឆ្នាំ២០១២ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុខគីម ភេទស្រី អាយុ ២៨ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃ ផ្ទះជួល [redacted] សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។

## ឯដំណើររឿងមានដូចតទៅ

កាលពីថ្ងៃទី ១១ ខែមីនា ឆ្នាំ២០១២ វេលាម៉ោង ២៣ និង១៥នាទី នៅចំណុចផ្ទះហ្គេមម្លូកហាត់សាច់ដុំ ផ្លូវលេខ ៦៣ កែងផ្លូវលេខ ១៨០ សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ មានករណីលួចមានស្ថានទម្ងន់ទោស (វាយយកទ្រព្យសម្បត្តិអ្នកដទៃ) មួយកើតឡើង ដែលបង្កឡើងដោយឈ្មោះ [redacted] បុត្រទី បានធ្វើសកម្មភាពចាប់ឈ្មោះ [redacted] សុខគីម ខ្ទប់មាត់ រួចគម្រាមយកលុយ ពេលនោះជនរងគ្រោះបើ ...

បម្រះ ហើយឈ្មោះ [redacted] បុត្រទី ក៏បានវាយលើឈ្មោះ [redacted] សុខគឹម មួយដៃ រួចចាប់យកខ្សែកពណ៌ប្រាក់មួយខ្សែ និងដោះចិញ្ចៀនដាំត្បូងមួយវង់ ហើយរត់គេចខ្លួន តែក្រោយមកសមត្ថកិច្ចក៏ចាប់ខ្លួនបាន រួមជាមួយវត្ថុតាង ដើម្បីយកទៅសាកសួរ។

បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៨១ ក្រ១ "ង" ចុះថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅៈ

- ផ្តន្ទាទោសលើឈ្មោះ [redacted] បុត្រទី ភេទប្រុស អាយុ ២៥ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០៣ឆ្នាំ តែទោសនេះអនុវត្តក្នុងពន្ធនាគារកំណត់ ០២ឆ្នាំ សល់ពីនេះត្រូវព្យួរ ពីបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចផ្ទះល្វែងប្លុកហាត់សាច់ដុំ ផ្លូវលេខ ៦៣ កែងផ្លូវលេខ ១៨០ សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី ១១ ខែមីនា ឆ្នាំ២០១២ តាមបញ្ញត្តិមាត្រា ៣៥៣, ៣៥៧, ១០៧ និង ១០៨ នៃក្រមព្រហ្មទណ្ឌ។

សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី ២៨ ខែសីហា ឆ្នាំ២០១២ និងប្រកាសជាសាធារណៈនៅថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ២០១២ ចំពោះមុខជនជាប់ចោទ មេធាវីការពារជនជាប់ចោទ និងកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី រក្សាសិទ្ធិប្តឹងទាស់ និងឧទ្ធរណ៍តាមកំណត់ច្បាប់។

- បានឃើញ សេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខ ៦៦៨ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០១២ របស់ជនជាប់ចោទឈ្មោះ [redacted] បុត្រទី សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៨១ ក្រ១ ង ចុះថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

- បានឃើញរបាយការណ៍រឿងរបស់ចៅក្រមសាលាឧទ្ធរណ៍។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការអមសាលាឧទ្ធរណ៍។

## នាពេលសវនាការ

ប្រធានក្រុមប្រឹក្សាសង្ខេបអង្គហេតុរឿង

ក្រឡាបញ្ជីអានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុខគឹម បានឆ្លើយនៅសាលាដំបូងរាជធានីភ្នំពេញ។

-ជនជាប់ចោទឈ្មោះ [redacted] បុត្រទី ឆ្លើយថា ខ្លួនសុំយកចម្លើយដែលបានឆ្លើយនៅសវនាការសាលាដំបូងដដែល ខ្លួនមិនទទួលស្គាល់ចម្លើយនៅនគរបាល នៅអយ្យការ និងនៅចៅក្រមស៊ើបសួរទេ ព្រោះចម្លើយទាំងនេះខ្លួន មានការភ័ន្តច្រឡំ ហើយពេលនោះខ្លួនស្រវឹង។ ខ្លួនប្តឹងឧទ្ធរណ៍មកនេះដើម្បីសុំឲ្យតុលាការបន្ធូរបន្ថយទោស។ ខ្លួនផឹកស្រាជាមួយឈ្មោះ តោ ខ្លួនផឹកច្រើនអត់ដឹងខ្លួនទេ ពេលខ្លួនប្រព្រឹត្តខ្លួនស្រវឹងអត់ដឹងខ្លួន ចំពោះជនរងគ្រោះខ្លួនអត់ស្គាល់ទេ ពេលប៉ូលីសចាប់ខ្លួនមិនបានដកហូតអ្វីពីខ្លួនទេ ហើយក៏មិនមានខ្សែក ចិញ្ចៀនដែរ។ សំណូមពរ សុំតុលាការបន្ធូរបន្ថយទោសឲ្យខ្លួន ដើម្បីខ្លួនកែប្រែជាពលរដ្ឋល្អ។

## សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ជនជាប់ចោទឆ្លើយនៅនគរបាលផ្សេង ហើយពេលនេះជនជាប់ចោទបានឆ្លើយថា ខ្លួនមានការភ័ន្តច្រឡំក្នុងការប្រព្រឹត្ត ដូច្នេះ សុំតម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៨១ ក្រ១ "ង" ចុះថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល។

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

ឆ្លងតាមការសួរដេញដោល ការឆ្លើយរបស់កូនក្តីខ្លួនមានលក្ខណៈមិនហ្នឹងហ្ន ហើយមិនបានឆ្លើយទទួលស្គាល់ទង្វើរបស់គាត់នៅសមត្ថកិច្ចទេ គឺគាត់ទទួលស្គាល់ចម្លើយនៅសាលាដំបូង ហើយពេលដែលគាត់ប្រព្រឹត្តនោះគាត់ថា គាត់ស្រវឹងខ្លាំង ហើយគាត់មិនដឹងខ្លួនថា បានប្រព្រឹត្តផង ចំពោះភាគីដើមបណ្តឹងក៏បានដកពាក្យបណ្តឹងដែរ ដោយថា មានការភ័ន្តច្រឡំ និងមិនទាមទារសំណង សំណូមពរ សុំកែប្រែចំណុចទោសឲ្យកូនក្តីខ្លួនបានទាប ដើម្បីបានកែប្រែខ្លួនជាពលរដ្ឋល្អ។

- ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ
- ក្រោយពីបានស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ
- ក្រោយពីបានពិភាក្សា វែកញែក ល្អិតល្អន់ តាមច្បាប់។

## សាលាឧទ្ធរណ៍ភ្នំពេញ

## យល់ឃើញថា៖

១- បណ្តឹងឧទ្ធរណ៍លេខ ៦៦៨ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០១២ របស់ឈ្មោ[redacted] បុត្រទី ជាជនជាប់ចោទ ធ្វើនៅក្នុងកំណត់ច្បាប់ តាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២- កាលពីថ្ងៃទី ១១ ខែមីនា ឆ្នាំ២០១២ មានសកម្មភាពលួចដោយហឹង្សាមួយបានកើតឡើងនៅចំណុចផ្ទះហ្គេមប្លុកហាត់សាច់ដុំ ផ្លូវលេខ ៦៣ កែងផ្លូវលេខ ១៨០ សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ បង្កឡើងដោយជនជាប់ចោទទៅលើនារីរងគ្រោះ

- ករណីនេះជនជាប់ចោទបានឆ្លើយសារភាពថា កាលពីថ្ងៃកើតហេតុនោះខ្លួនពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន ប៉ុន្តែដោយសារពេលនោះ ខ្លួនផឹកស្រាស្រវឹងខ្លាំងពេកបណ្តាលឲ្យបាត់បង់ស្មារតីទទួលខុសត្រូវ ក៏ធ្វើដោយភ្លេចភ្លាំងភ័ន្តច្រឡំ ហើយថា ខ្លួនមានការសោកស្តាយយ៉ាងខ្លាំង និងរាងចាលលែងធ្វើយ៉ាងហ្នឹងទៀតហើយ ខ្លួនបានកែប្រែគំនិតមារយាទឲ្យបានទៅជាកូនល្អវិញហើយ។ ការប្រព្រឹត្តនេះ គឺជាលើកទី ១ របស់ខ្លួន ឯរបស់ដែលខ្លួនទទួលបាន ក៏មិនមានតម្លៃច្រើនដែរ។

៣- មានពិរុទ្ធលើជនជាប់ចោទ ពីបទ លួចដោយហឹង្សា ប្រព្រឹត្តនៅចំណុចផ្ទះហ្គេមប្លុកហាត់សាច់ដុំ ផ្លូវលេខ ៦៣ កែងផ្លូវលេខ ១៨០ សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី ១១ ខែមីនា ឆ្នាំ២០១២ បទល្មើសមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣. ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

៤- ដោយជនជាប់ចោទទើបតែប្រព្រឹត្តជាលើកទី ១ ហើយប្រព្រឹត្តក្នុងភាពស្រវឹងខ្លាំង បាត់បង់ស្មារតីទទួលខុសត្រូវ និងបានកែប្រែខ្លួនបានល្អ គួរពិចារណាលើការអនុវត្តទោសរបស់ជនជាប់ចោទឡើង វិញឲ្យបានសមស្រប។

៥- សាលក្រមព្រហ្មទណ្ឌលេខ ៨១ ក្រ១ "ង" ចុះថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ២០១២ សម្រេចមានភាពត្រឹមត្រូវ គួរតម្កល់ទុកជាបានការ លើកលែងតែការអនុវត្តទណ្ឌកម្ម គួរកែប្រែដូចយល់ឃើញខាងលើ។

## ហេតុដូច្នេះ
## វិនិច្ឆ័យសេចក្ដី

១- ទទួលបណ្ដឹងឧទ្ធរណ៍លេខ ៦៦៨ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០១២ របស់ឈ្មោះ [redacted]បុត្រទី ជាជនជាប់ចោទ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់។

២- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៨១ ក្រ១ "ង" ចុះថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ លើកលែងតែការអនុវត្តទណ្ឌកម្មដាក់ពន្ធនាគារត្រូវកែប្រែជា បង្គាប់ឲ្យជនជាប់ចោទអនុវត្តទណ្ឌកម្មនៅក្នុងពន្ធនាគារកំណត់ ០១ (មួយ) ឆ្នាំ គិតពីថ្ងៃឃាត់ខ្លួនថ្ងៃទី ១១ ខែមីនា ឆ្នាំ២០១២ ឯទោសសល់ពីនេះត្រូវព្យួរធម្មតា។

ក្រៅពីនេះទុកនៅដដែល។

សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ១៤ ខែមករា ឆ្នាំ២០១៣ និងប្រកាសជាសាធារណៈនៅថ្ងៃទី ២៤ ខែមករា ឆ្នាំ២០១៣ ចំពោះមុខជនជាប់ចោទ មេធាវីការពារជនជាប់ចោទ បើកផ្លូវសាទុក្ខ ០១ ខែ គិតចាប់ពីថ្ងៃនេះទៅ។

**សេចក្ដីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកម្លាំងគ្រប់ថ្នាក់គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះ ឲ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។**

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted], [redacted] | ហត្ថលេខា: [redacted] |

---

| | |
|---|---|
| បានឃើញ<br>ប្រធានសាលាឧទ្ធរណ៍<br>[redacted] | ចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម<br>ភ្នំពេញ, ថ្ងៃទី 04 ខែ 6..... ឆ្នាំ ២០១៤<br>ក្រឡាបញ្ជី |